ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

**សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល**

**ស្តីពី**

**ការប្រយុទ្ធទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩**

ក្រសួងសុខាភិបាលសូមជម្រាបជូនសាធារណជនថា នៅក្នុងសភាពការបច្ចុប្បន្នដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ ប៉ុន្តែក្នុងពេលនេះ កម្ពុជាមិនទាន់មានការរាតត្បាតក្នុងសហគមន៍របស់យើងនៅឡើយទេ។ ករណីទាំងអស់សុទ្ធតែជាករណីនាំចូលពីក្រៅប្រទេស។

ដោយមានការសម្រេចពីរាជរដ្ឋាភិបាល ក្រសួងសុខាភិបាលសហការជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញនឹងប្រើប្រាស់សណ្ឋាគារ Great DUKE (អតីតសណ្ឋាគារអាំងទែកុងទីណង់តាល់) ជាមន្ទីរពេទ្យសម្រាប់ពិនិត្យ ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ១៩។

ដើម្បីបញ្ចៀសនូវការចម្លងក្នុងសហគមន៍ជាយថាហេតុ រាជរដ្ឋាភិបាលបានឲ្យក្រសួងសុខាភិបាលសហការជាមួយកងកម្លាំងសុខាភិបាលនៃកងយោធពលខេមរភូមិន្ទរបស់ក្រសួងការពារជាតិ និងកងកម្លាំងសុខាភិបាលនៃនគរបាលជាតិរបស់ក្រសួងមហាផ្ទៃ ដើម្បីរួមសហការគ្នាប្រយុទ្ធនឹងជំងឺកូវីដ១៩ ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាប និងរក្សាភាពនឹងនរក្នុងចិត្តកុំមានការភ័យខ្លាច ជឿទុកចិត្តលើវិធានការប្រយុទ្ធនឹងជំងឺកូវីដ១៩នេះ របស់រាជរដ្ឋាភិបាល។

ក្រសួងសុខាភិបាលបន្តអំពាវនាវឲ្យប្រជាពលរដ្ឋរបស់យើងថែរក្សាអនាម័យដៃ ខ្លួនប្រាណ ចំណីអាហារ និងបរិស្ថានជុំវិញខ្លួនឲ្យបានជាប់ជាប្រចាំ។

ថ្ងៃអង្គារ ៩រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

ម៉ម ប៊ុនហេង